# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 46

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងសិក្សាការលើកកម្ពស់ការប្រគួតប្រជែងរបស់កំពង់ផែភ្នំពេញ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/21

កាលបរិច្ឆេទបញ្ចប់គម្រោង 01/01/22

៣. ចំណាយគម្រោងសរុប $9,700,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងសាធារណការ និងដឹកជញ្ជូន

RESPONSIBLE UNIT General Department of Logistic

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានភស្តុភារកម្ម

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលក្នុងរាំងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះ នឹងសាងសង់កន្លែងលើកដាក់ទំនិញ របាំងការពារលេក និងចំណតកាប៉ាល់តាមបណ្តោយទន្លេមេគង្គ និងទន្លេសាប នៅក្នុងតំបន់ពាណិជ្ជកម្មកំពង់ផែស្វយ័តភ្នំពេញ (PPAP) ព្រមទាំងសាងសង់ឃ្លាំងនិងមជ្ឈមណ្ឌលភស្តុភារនៅរាជធានីភ្នំពេញ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. **វិស័យ** (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន Ports and Waterways

១២. **ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

កម្មវត្ថុនៃគម្រោង អាចត្រូវបានសង្ខេបដូចខាងក្រោម៖
- លើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក តាមទន្លេមេគង្គ និងទន្លេសាប
- សម្របសម្រួលប្រកបដោយប្រសិទ្ធភាព នៃវិស័យកស្តុភារនៅជុំវិញរាជធានីភ្នំពេញ
- បន្ថយតម្លៃដឹកជញ្ជូន និងផ្តល់នូវសេវាកម្មកស្តុភារដែលមានលក្ខណៈល្អប្រសើរជាងមុន
- ផ្តល់នូវសុវត្ថិភាពក្នុងការលើកដាក់ទំនិញ និងសម្រួលដល់ការរក្សាទុកទំនិញ

សម្រាប់ប្រតិបត្តិការផ្ទេរទំនិញគ្រោះថ្នាក់នៅក្នុងតំបន់កំពង់ផែ ស្របតាមការអនុវត្តកិច្ចព្រមព្រៀងក្នុងចំណោមប្រទេសអាស៊ាន។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះ នឹងសាងសង់កន្លែងលើកដាក់ទំនិញ របាំងការពារលក និងចំណតកាប៉ាល់តាមបណ្តោយទន្លេមេគង្គ និងទន្លេសាប នៅក្នុងតំបន់ពាណិជ្ជកម្មកំពង់ផែស្វយ័តភ្នំពេញ (PPAP) ព្រមទាំងសាងសង់ឃ្លាំងនិងមជ្ឈមណ្ឌលកស្តុភារនៅរាជធានីភ្នំពេញ។

គម្រោងនេះ មានសមាសភាគចំនួន ៧ដូចជា៖
- ពង្រីកកំពង់ផែភ្នំពេញ ថ្មី
- លើកកម្ពស់សេវាកម្មរបស់កំពង់ផែ ដូចជា មជ្ឈមណ្ឌលកស្តុភារ ។ល។
- ការបង្កើតតំបន់ទំនិញគ្រោះថ្នាក់ រាប់បញ្ចូលទាំងប្រតិបត្តិការ និងការគ្រប់គ្រង
- កសាងសមត្ថភាព សម្រាប់ការថែរក្សាប្រព័ន្ធនាំផ្លូវ
- ប្រព័ន្ធគ្រប់គ្រងពត៌មានវិទ្យាសម្រាប់តាមដាននាវា
- បង្កើតចំណតពហុបំណង នៅតាមទន្លេ
- បង្កើតយុទ្ធសាស្ត្រលើកកម្ពស់កំពង់ផែ និងជម្រុញការលក់

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កំពង់ផែភ្នំពេញ ថ្មី គឺមានទីតាំងនៅជិតទីតាំងដើមរបស់ខ្លួន និងជាគោលដៅទាំងការនាំចេញនិងការនាំចូល។ ហេតុនេះហើយ ការពង្រីកកំពង់ផែដើម្បីឆ្លើយតបទៅនឹងតម្រូវការ គឺមានប្រសិទ្ធភាព ធ្វើឱ្យការនាំចេញទំនិញមានភាព ប្រកួតប្រជែងជាមុន តាមរយៈការកាត់បន្ថយថ្លៃដឹក។ ផ្អែកទៅតាមតម្រូវការនៃទំនិញកុងទឺន័រចេះតែកើនឡើង វាគឺមានភាពចាំបាច់ខ្លាំងណាស់ការគាំទ្រដល់ការលើកដាក់ទំនិញឱ្យមានភាពរលូនទៅ និងចេញពីកំពង់ផែ។ ប្រទេសសមាជិកអាស៊ាន បានឯកភាពលើពិធីសារទំនិញគ្រោះថ្នាក់ (ដូចជាសារធាតុផ្ទុះ, សាធាតុរាវឆេះ, ឧស្ម័នឆេះ, និងសារធាតុដែលបង្កឱ្យមានការផ្ទុះជាដើម) និងបានអនុញ្ញាតឱ្យដឹកទំនិញទាំងនោះឆ្លងកាត់ប្រទេសរបស់ពួកគេ។ ក្នុងការតភ្ជាប់នេះ PPAP ត្រូវតែផ្តល់នូវសុវត្ថិភាពក្នុងការលើកដាក់ និងសម្រួលដល់ការរក្សាទុកទំនិញគ្រោះថ្នាក់ទាំងនោះ។ ក្រៅពីនេះ ការមើលថែទាំប្រព័ន្ធនាំផ្លូវ ក៏ជាការចាំបាច់ផងដែរ ពីព្រោះស្ថានភាពបាតទន្លេជារឿយៗ មានការផ្លាស់ប្តូរអាស្រ័យទៅតាមជំនន់ទឹកទន្លេមេគង្គ។ សុវត្ថិភាពសម្រាប់ការនាំផ្លូវ ជាពិសេសនៅពេលយប់ គឺធានានូវស្ថេរភាព និងតម្លៃទាបនៃការដឹកជញ្ជូនតាមផ្លូវទឹក ដែលនឹងធ្វើឱ្យPPAP មានភាពប្រកួតប្រជែងជាងមុន។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោងមានដូចតទៅ៖
- o ប្រទេសកម្ពុជាទាំងមូល
- o ប្រជាជនកម្ពុជាទូទាំងប្រទេស
- o ក្រសួងសាធារណការ និងដឹកជញ្ជូន
- o យុវជនកម្ពុជាជំនាន់ក្រោយ

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងពុំមានផលប៉ះពាល់ដល់បរិស្ថាន និងប្រជាជនមូលដ្ឋាននោះទេ។ គម្រោងនេះ នឹងផ្តល់ជូនប្រទេសកម្ពុជា និងប្រជាជនកម្ពុជានូវអត្ថប្រយោជន៍ជាច្រើន ពីព្រោះគម្រោងនេះនឹងផ្តល់ភាពងាយស្រួលដល់ការដឹកជញ្ជូន ជាពិសេសតាមផ្លូវទឹក ដែលមានភាពងាយស្រួល និងចំណាយតិច ។ លើសពីនេះ គម្រោងនេះក៏នឹងចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅលើផ្លូវគោកផងដែរ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការកាត់បន្ថយ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**សម្រាប់កម្រោងនេះ ទោះបីស្ថិតនៅទីតាំងកន្លែងណាក៏ដោយ វាពុំមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីទេ ប៉ុន្តែផ្ទុយទៅវិញគម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ផលប្រយោជន៍បុរសនិងស្ត្រីជាច្រើននៅក្នុងពេលអនុវត្ត គម្រោង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានជំនាញ និងបទពិសោធន៍មួយចំនួនសម្រាប់ការអនុវត្ត។ ប៉ុន្តែ យើងត្រូវការមនុស្សដែលមានជំនាញ និងបទពិសោធន៍ ព្រមទាំងការបណ្តុះបណ្តាលនៅក្រៅប្រទេស ដើម្បីជាជំនួយបន្ថែម ពីព្រោះគម្រោងនេះហាក់បីដូចជាថ្មីសម្រាប់ប្រទេសកម្ពុជា និងត្រូវការបទពិសោធន៍តាមរយៈការអនុវត្តកន្លងមកនៅបរទេស។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងនឹងដំណើរការតាមការគ្រោងទុកបើសិនជាមានថវិកាគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោង។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

o ជប៉ុន
o សាធារណរដ្ឋប្រជាមានិតចិន
o កូរ៉េ

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 4,850.0 | 4,850.0 | 0.0 | 9,700.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 4,850.0 | 4,850.0 | 0.0 | 9,700.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 4,850.0 | 4,850.0 | 0.0 | 9,700.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 4,850.0 | 4,850.0 | 0.0 | 9,700.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: